# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម ជស/រកម/០៣៩៨/០៤

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

◇ ◇ ◇ ◇

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ០១នស៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្កើតគណនីពិសេសរបស់ធនាគារជាតិ សម្រាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការបង្កើតគណនីពិសេសរបស់ធនាគារជាតិ

# សំរាប់

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .- ត្រូវបើកនៅក្នុងបញ្ជីគណនីនៃរតនាគារជាតិ នូវគណនីពិសេសមួយ ហៅថា គណនីពិសេសរបស់រតនាគារសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គណនីពិសេសនេះ ក៏ត្រូវ មូលនិធិឧបត្ថម្ភការបោះឆ្នោត សំរាប់អោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ២ .- ធនធានទាំងឡាយ នៃគណនីពិសេសនេះបានមកពី :

- វិភាគទាន នៃថវិកាជាតិ
- អំណោយបរិច្ចាគរបស់សហគមន៍អន្តរជាតិ
- ចំណូលស្របច្បាប់ផ្សេង ៗ ទៀត

មាត្រា ៣ .- ធនធានទាំងឡាយ នៃគណនីពិសេសនេះត្រូវបានប្រើប្រាស់ ដើម្បីទូទាត់ចំណាយទាំងឡាយក្នុងការចាត់ចែងកិច្ចការបោះឆ្នោត រួមទាំងចំណាយសំរាប់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់ភ្នាក់ងារដែលត្រូវជ្រើសរើសដោយគណៈអាជ្ញាសំរាប់កិច្ចប្រតិបត្តិការបោះឆ្នោតផង ។

មាត្រា ៤ .- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំ ប្លង់ថវិកាចំណូល និងថវិកាចំណាយតាមកម្រិតចន្លោះពេលវេលា និងត្រូវបញ្ជូនទៅរដ្ឋសភា ដោយផ្ញើអត្ថបទចម្លងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក៏ត្រូវផ្សព្វផ្សាយជូនដល់សាធារណៈ ។ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ត្រូវរៀបចំធ្វើរបាយការណ៍ ស្ដីពីការអនុវត្តន៍ថវិកាចំណូល និងថវិកាចំណាយក្នុងរយៈពេលមិនហួសពីបីខែ បន្ទាប់ពីពេលបោះឆ្នោត ។ របាយការណ៍នេះ ត្រូវបញ្ជូនទៅរដ្ឋសភា ដោយផ្ញើអត្ថបទចម្លងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវផ្សព្វផ្សាយជូនដល់ជាសាធារណៈដែរ ។

មាត្រា ៥ .- ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអាណាប័កដើមខ្ទង់នៃគណនីពិសេសរបស់រតនាគារជាតិសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងត្រូវមានអាណាប័កតាមការប្រទានសិទ្ធិម្នាក់ ឬច្រើននាក់ជាជំនួយការ ដែលតែងតាំងឡើង និងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាណាប័កដើមខ្ទង់ផ្ទាល់ ។

កិច្ចប្រតិបត្តិការនៃគណនីពិសេសរបស់រតនាគារជាតិ សំរាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រត្រូវឋិតនៅក្រោមច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងត្រូវអនុលោមតាមបទបញ្ញត្តិស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងស្ដីពីលទ្ធកម្មសាធារណៈ ។

អង្គភាពពិនិត្យហិរញ្ញវត្ថុ នៃឥណទានថវិកាជាតិនេះ ត្រូវតាក់តែងឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការយល់ព្រមពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៦ .- សម្រាប់ចំណាយដែលបានចុះកិច្ចសន្យាចំណាយ ឬបញ្ជាចំណាយលើឥណទានថវិកានេះ មិនត្រូវលើសពីកម្រិតចំណាយដែលមានកំណត់ក្នុងច្បាប់ នៃឥណទានថវិកានេះទេ ។

ប្រាក់ដែលសល់ពីការចំណាយលើឥណទានថវិកានេះ ក្រោយបញ្ចប់ការចំណាយដែលមិនបានបញ្ចូលទៅក្នុងក្របខ័ណ្ឌកម្មវិធីរបស់ខ្លួនជាប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ និងភ្នាក់ងារផ្សេងៗ ត្រូវបានបញ្ចូលទៅរតនាគារជាតិ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងរាជរដ្ឋាភិបាលត្រូវព្រមព្រៀងគ្នាលើការប្រើប្រាស់ទុនបម្រុងដែលមានក្នុងបញ្ជីនៃឥណទានថវិកានេះ ប្រសិនបើមាន ។

## ជំពូកទី ២

## មូលនិធិឧបត្ថម្ភ នៃថវិកាជាតិ

## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២

មាត្រា ៧ .- អនុញ្ញាតឱ្យផ្ទេរឥណទានចំនួនដប់ប្រាំបីពាន់លាន ( ១៨.០០០.០០០.០០០ ) រៀល ពីថវិកាជាតិឆ្នាំ ១៩៩៨ ចូលជាមូលនិធិឧបត្ថម្ភនៃគណនីពិសេសរបស់រតនាគារជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

មាត្រា ៨ .- រាល់បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩ .- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★ ★ ★